# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ...០១២........ន. គ. ស ឈ.ស.ណ.

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០២២

# សេចក្តីជូនដំណឹង
## សម្រាប់បេក្ខជនត្រូវចូលរួមប្រឡងប្រជែងជ្រើសរើសមន្ត្រីលក្ខន្តិកៈចំនួន ២០ រូប ចូលបម្រើការងារនៅនិយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជនចូលបម្រើការងារនៅនិយ័តករគណនេយ្យ និងសវនកម្ម (**ន.គ.ស.**)នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សូមជូនដំណឹងដល់បេក្ខជនទាំងពីរភេទ ដែលត្រូវចូលរួមប្រឡងប្រជែងនៅ **មណ្ឌលវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ត្រូវគោរពតាមកាលបរិច្ឆេទ និងពេលវេលាកំណត់ដូចខាងក្រោម÷

**១. សម័យប្រឡង÷ នៅថ្ងៃអាទិត្យ ទី ២៤ ខែ មេសា ឆ្នាំ ២០២២**

**-ពេលព្រឹក**

- ម៉ោង ៧:០០-៨:៣០ : ស្កេនមេដៃ ពិនិត្យវត្តមាន ធ្វើ Rapid Test Covid-19 ប្រកាសបទប្បញ្ញត្តិ និងចែកសន្លឹកកិច្ចការដល់បេក្ខជន
- ម៉ោង ៨:៣០-១១:៣០ : វិញ្ញាសាចំណេះដឹងទូទៅ និងភាសាអង់គ្លេស។

**-ពេលរសៀល**

- ម៉ោង ១២:៣០-១:៣០ : ស្កេនមេដៃ ពិនិត្យវត្តមាន ធ្វើ Rapid Test Covid-19 ប្រកាសបទប្បញ្ញត្តិ និងចែកសន្លឹកកិច្ចការដល់បេក្ខជន
- ម៉ោង ២:០០-៤:០០ : វិញ្ញាសាដោយឡែក (ប្រែប្រួលតាមជំនាញ)។

**២.វិញ្ញាសាប្រឡង**

**២.១.វិញ្ញាសារួម**

- ចំណេះដឹងទូទៅ ÷ រយៈពេល ២ ម៉ោង
- ភាសាអង់គ្លេស ÷ រយៈពេល ១ ម៉ោង។

**២.២.វិញ្ញាសាដោយឡែក**

**ក.ផ្នែកគណនេយ្យ÷**ចំណេះដឹងអំពីវិស័យគណនេយ្យនិងការងារគណនេយ្យ(រយៈពេល២ម៉ោង)។

**ខ.ផ្នែកច្បាប់និងរដ្ឋបាល÷** ចំណេះដឹងអំពីវិស័យច្បាប់និងរដ្ឋបាល (រយៈពេល២ម៉ោង)។

**គ.ផ្នែកព័ត៌មានវិទ្យា÷** ចំណេះដឹងអំពីព័ត៌មានវិទ្យា (រយៈពេល២ម៉ោង)។

**ឃ.ផ្នែកទំនាក់ទំនងអន្តរជាតិ÷**ចំណេះដឹងអំពីវិស័យទំនាក់ទំនងអន្តរជាតិពាក់ព័ន្ធនឹងវិស័យគណនេយ្យនិងសវនកម្ម សរសេរជាភាសាអង់គ្លេស (រយៈពេល២ម៉ោង)។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
ទូរស័ព្ទ ០៨៥ - ២៣ ៨៨២ ១១១
Phone: 023 882 111

**៣. បញ្ជីរាយនាមបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (shortlist)** ដើម្បីចូលរួមប្រឡងនឹងមានបិទផ្សាយនៅ**វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ឬបេក្ខជនអាចទទួលព័ត៌មាននៅក្នុងគេហទំព័ររបស់និយ័តករគណនេយ្យនិងសវនកម្ម www.acar.gov.kh ឬតាមបណ្តាញទំនាក់ទំនងសង្គម Facebook Page : និយ័តករគណនេយ្យនិងសវនកម្ម ឬតាមប្រព័ន្ធឆានែលតេឡេក្រាម ដែលមានឈ្មោះថា **ព័ត៌មានគណនេយ្យនិងសវនកម្មកម្ពុជា** ចាប់ពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ តទៅ។

**៤. បេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (shortlist)** ត្រូវមកស្កេនមេដៃ ***ដើម្បីមកទទួលសលាកប័ត្រឯកត្តជន*** នៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានទីតាំងនៅផ្លូវលេខ ១៣៤ សង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក រាជធានីភ្នំពេញចាប់ពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ៥:០០ ល្ងាច។

**៥. ប្លង់មណ្ឌលប្រឡង, បញ្ជីរាយនាមបេក្ខជនតាមបន្ទប់, លេខតុ និង QR Code មានរូបថត៖** នឹងត្រូវបិទផ្សាយនៅមណ្ឌលប្រឡងនៅ **វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ឬបេក្ខជនអាចទទួលព័ត៌មាននៅក្នុងគេហទំព័ររបស់និយ័តករគណនេយ្យនិងសវនកម្ម www.acar.gov.kh ឬតាមបណ្តាញទំនាក់ទំនងសង្គម Facebook Page និយ័តករគណនេយ្យនិងសវនកម្ម ឬតាមប្រព័ន្ធឆានែលតេឡេក្រាមដែលមានឈ្មោះថា **ព័ត៌មានគណនេយ្យនិងសវនកម្មកម្ពុជា** ចាប់ពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ ចាប់ពីម៉ោង៨:០០ព្រឹក ដល់៥:០០ ល្ងាច ។

**៦. បេក្ខជនត្រូវធ្វើតេស្តរហ័ស (rapid test) ដើម្បីបង្ការការឆ្លងវីរុសរាលដាលជំងឺកូវីដ-១៩៖ (ធ្វើខ្លួនឯង)**

- កាលបរិច្ឆេទ : ថ្ងៃទី២៤ ខែមេសាឆ្នាំ២០២២ ចាប់ពីម៉ោង ៧:០០នាទី តទៅ
- ទីកន្លែង : វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ឧបករណ៍ធ្វើតេស្តរហ័ស : និយ័តករគណនេយ្យនិងសវនកម្ម ផ្តល់ជូន

**៦. ឯកសារភ្ជាប់៖**

បេក្ខជនដែលមានឈ្មោះចូលរួមប្រឡងប្រជែងត្រូវត្រៀមលក្ខណៈជាមុននូវឯកសារដូចជា៖សាលាកបត្រឯកត្តជន អត្តសញ្ញាណប័ណ្ណ ឬប័ណ្ណសម្គាល់និស្សិត ឬកាតមន្ត្រីរាជការ/បុគ្គលិក និងពាក្យស្នើសុំកែតម្រូវព័ត៌មានជាដើម។

**បញ្ជាក់៖** បេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (ជាប់ shortlist) នឹងត្រូវដាក់ជាសមាជិកក្រុមបណ្តាញតេឡេក្រាម (telegram channel) មានឈ្មោះ **"ការជ្រើសរើសបេក្ខជនចំនួន ២០ រូប ឱ្យចូលបម្រើការងារជាមន្ត្រីលក្ខន្តិកៈនៅនិយ័តករគណនេយ្យនិងសវនកម្ម"**។ បណ្តាញនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្សព្វផ្សាយព័ត៌មានដល់បេក្ខជនឱ្យកាន់តែឆាប់រហ័សតែប៉ុណ្ណោះ។

បេក្ខជនអាចសាកសួរព័ត៌មានផ្សេងៗបន្ថែម តាមរយៈលេខទូរស័ព្ទ០២៣ ៨៨២ ១១១ ឬ ០៩២ ២៥០ ៧១២ ឬ ០៧០ ៤៩៥ ៩០០ ឬមកសាកសួរព័ត៌មាននៅការិយាល័យរដ្ឋបាល និងបុគ្គលិក **ន.គ.ស.** តែម្តង។

អាសយដ្ឋាននិយ័តករគណនេយ្យនិងសវនកម្ម៖ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**និយ័តករគណនេយ្យនិងសវនកម្ម**